WWF- កម្ពុជា
ផ្ទះលេខ ២១ ផ្លូវលេខ ៣២២
សង្កាត់បឹងកេងកង១
ប្រអប់សំបុត្រលេខ ២៤៦៧
ភ្នំពេញ

ទូរស័ព្ទ៖ +៨៥៥ ២៣ ២១៨ ០៣៤
ទូរសារ៖ +៨៥៥ ២៣ ២១១ ៩០៩
www.cambodia.panda.org

**សេចក្តីប្រកាសសារពត៌មាន**

**សម្រាប់ការចេញផ្សាយបន្ទាន់**

# តារាភាពយន្តកម្ពុជាជើងចាស់មានកេរ្តិ៍ឈ្មោះល្បី អំពាវនាវឲ្យអ្នកគាំទ្រខ្លួន ធ្វើសកម្មភាពដើម្បីភពផែនដី

នៅតែ១០ថ្ងៃទៀតប៉ុណ្ណោះសម្រាប់ឈានដល់ការប្រារព្ធទិវា "មួយម៉ោងសម្រាប់ភពផែនដី" ឬហៅថា Earth Hour **លោក ទេព រិនដារ៉ូ** និង **លោក យុត្តារា ឆាន្នី** កំពុងគាំទ្រសកម្មភាពយុទ្ធនាការណ៍ "មួយម៉ោងសម្រាប់ភពផែនដី" ហើយស្នើសុំអ្នកពេញចិត្ត និងគាំទ្រស្នាដៃសម្តែងសិល្បៈភាពយន្តរបស់ខ្លួន ឲ្យធ្វើសកម្មភាពដើម្បីរួមចំណែកជួយការពារភពផែនដី។ នេះគឺជាឆ្នាំទី២ហើយ ដែលតារាទាំងពីររូបនេះបានចូលរួមក្នុងសកម្មភាពយុទ្ធនាការណ៍ ជាមួយអង្គការ WWF ដើម្បីលើកទឹកចិត្តប្រជាជនកម្ពុជានៅទូទាំងប្រទេសឲ្យចូលរួមប្រារព្ធទិវា "មួយម៉ោងសម្រាប់ភពផែនដី"។

លោក ទេព រិនដារ៉ូ ដែលទើបបានទទួលពានរង្វាន់ជាតារាភាពយន្តដែលមានប្រជាប្រិយភាពបំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា នឹងប្រារព្ធទិវា "មួយម៉ោងសម្រាប់ភពផែនដី" ដោយបិទភ្លើងរយៈពេលមួយម៉ោង នៅថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១២ ចាប់ពីម៉ោង៨៖៣០ ដល់ ៩៖៣០យប់។

លោក បានបន្តថា៖"យើងម្នាក់ៗត្រូវមានការទទួលខុសត្រូវចំពោះនិរន្តរភាពនៃភពផែនដីរបស់យើង ហើយយើងអាចធ្វើឲ្យមានការផ្លាស់ប្តូរជាវិជ្ជមានបាន។ ខ្ញុំនឹងបិទភ្លើងរយៈពេលមួយម៉ោងដើម្បីប្រារព្ធទិវា Earth Hour ឆ្នាំនេះ។ សូមចូលរួមប្រារព្ធជាមួយខ្ញុំ។"

ទិវា "មួយម៉ោងសម្រាប់ភពផែនដី" ជាយុទ្ធនាការណ៍ធំជាងគេបង្អស់ស្តីពីការប្រែប្រួលអាកាសធាតុ ធ្វើឡើងដោយប្រជាជននៅជុំវិញពិភពលោក។ តាមរយៈទិវានេះ បុគ្គលម្នាក់ៗ ក្រុមហ៊ុនឯកជន សហគមន៍ សមាគមសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលនានា មានឱកាសបង្ហាញឆន្ទៈរបស់ខ្លួន លើកទឹកចិត្តដល់មិត្តភ័ក្តិ មិត្តរួមអាជីព និងអ្នករស់នៅជិតខាងខ្លួន ថែមទាំងមានឱកាសធ្វើសកម្មភាពដើម្បីជាប្រយោជន៍សម្រាប់បរិស្ថាន និងនិរន្តរភាពនៃភពផែនដី។

លោក យុត្តារា ឆាន្នី ស្នើសុំឲ្យប្រជាជនកម្ពុជាធ្វើសកម្មភាពផ្សេងទៀត ក្រៅពីការបិទភ្លើងមួយម៉ោងសម្រាប់ទិវា តាមរយៈការបន្តអនុវត្តសកម្មភាពដែលមាននិរន្តរភាពនៅក្នុងការរស់នៅប្រចាំថ្ងៃ។

លោក បានបន្ថែមថា៖ "ភពផែនដីជារបស់យើងទាំងអស់គ្នា ហើយបុគ្គលម្នាក់ៗអាចធ្វើសកម្មភាពដើម្បីរួមចំណែកមួយផ្នែកតូចដល់ការកាត់បន្ថយបរិមាណឧស្ម័នកាបូនិកបញ្ចេញទៅក្នុងបរិយាកាស និងធ្វើសកម្មភាពដទៃទៀតជាប្រចាំដើម្បីជាដំណោះស្រាយមួយចំពោះការប្រែប្រួលអាកាសធាតុ"។

WWF- កម្ពុជា
ផ្ទះលេខ ២១ ផ្លូវលេខ ៣២២
សង្កាត់បឹងកេងកង១
ប្រអប់សំបុត្រលេខ ២៤៦៧
ភ្នំពេញ

ទូរស័ព្ទ៖ +៨៥៥ ២៣ ២១៨ ០៣៤
ទូរសារ៖ +៨៥៥ ២៣ ២១១ ៩០៩
www.cambodia.panda.org

**សេចក្តីប្រកាសសារពត៌មាន** **សម្រាប់ការចេញផ្សាយបន្ទាន់**

សកម្មភាពសម្រាប់ភពផែនដីរបស់តារាភាពយន្តទាំងពីរ ជាគំរូដ៏ល្អមួយ ដែលលើកទឹកចិត្តអ្នកគាំទ្រខ្លួន ក្រុមគ្រួសារ និងមិត្តភ័ក្តិជាច្រើននាក់ឲ្យចូលរួមជាមួយប្រជាជននៅលើពិភពលោកក្នុងបុព្វហេតុរួមតែមួយគឺការការពារភពផែនដីរបស់យើង។

សូមអញ្ជើញប្រជាជនកម្ពុជា ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ ក្រុមគ្រួសារ សមាគម ក្រុមហ៊ុនឯកជន សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងភ្នាក់ងាររដ្ឋាភិបាលទាំងអស់ ចូលរួមជាមួយពិភពលោកក្នុងការបិទភ្លើងជានិមិត្តរូបរយៈពេលមួយម៉ោង ចាប់ពីម៉ោង ៨៖៣០ ដល់ ៩៖៣០យប់ នៅថ្ងៃទី៣១ ខែមិនា ឆ្នាំ២០១២ នេះ និងបន្តធ្វើសកម្មភាពផ្សេងទៀតដើម្បីរួមចំណែកជាដំណោះស្រាយមួយចំពោះការប្រែប្រួលអាកាសធាតុ។

**សម្រាប់ពត៌មានបន្ថែម សូមទាក់ទង:**

លោក ទេព អស្នារិទ្ធ
ការិយាល័យសារពត៌មាន និងកិច្ចការសាធារណៈ
អង្គការ WWF -កម្ពុជា
ទូរស័ព្ទ: +៨៥៥ (០)២៣ ២១៨ ០៣៤
អ៊ីមែល: asnarith.tep@wwf.panda.org

**ពត៌មានសម្រាប់អ្នកនិពន្ធ:**

ទិវា "មួយម៉ោងសម្រាប់ភពផែនដី" ត្រូវបានគេប្រារព្ធធ្វើឡើងដំបូងបង្អស់ នៅក្នុងទីក្រុងមួយ ក្នុងឆ្នាំ ២០០៧។ បច្ចុប្បន្នទិវានេះបានក្លាយជាចលនាសាកលលោកស្តីពីបរិស្ថានធំបំផុត ដែលត្រូវបានប្រជាជនចំនួន ជិត ២កោដ៍នាក់ ក្នុងទីក្រុងចំនួន ៥២៥១ នៅក្នុងប្រទេសចំនួន ១៣៥ នៅជុំវិញពិភពលោក ប្រារព្ធជារៀងរាល់ឆ្នាំ។

ឆ្នាំនេះ ក្រុមហ៊ុនឯកជនចំនួនជាង ១៥០ កន្លែងនៅក្នុងរាជធានីភ្នំពេញ ក្នុងខេត្តសៀមរាម ព្រះសីហនុ និងកោះកុង បានត្រៀមខ្លួនរួចជាស្រេចដើម្បីបិទភ្លើងជានិមិត្តរូបរយៈពេលមួយម៉ោង នៅថ្ងៃសៅរ៍ ទី៣១ ខែមិនា ឆ្នាំ២០១២ ចាប់ពីម៉ោង ៨៖៣០ ដល់ម៉ោង ៩៖៣០យប់ សម្រាប់ទិវា Earth Hour ។ ក្រុមហ៊ុនទាំងនោះមានដូចជា៖

| | |
|---|---|
| 1. Raffles Hotel Le Royal (Phnom Penh)<br>2. Raffles Grand Hotel D’Angkor (Siem Reap province)<br>3. Intercontinental Hotel<br>4. Cambodiana Hotel<br>5. Imperial Garden Villa and Hotel<br>6. Sunway Hotel Phnom Penh<br>7. Himawari Hotel Apartments<br>8. Amanjaya Pancam Hotel<br>9. K-West Restaurant<br>10. Le Moon Terrace<br>11. Amansara Resort | 40. Phnom Penh Indian Restaurant<br>41. Old Ponlok Restaurant<br>42. V-Silk Shop<br>43. Bopha Phnom Penh and Titanic Restaurant<br>44. Sinh Foo Restaurant<br>45. Tutti Fruit Frozen Yogurt<br>46. Bougainvillier Hotel<br>47. The Quay Hotel<br>48. Chow Restaurant<br>49. Foreign Correspondents Club (FCC)<br>50. Cafe Fresco |

WWF- កម្ពុជា
ផ្ទះលេខ ២១ ផ្លូវលេខ ៣២២
សង្កាត់បឹងកេងកង១
ប្រអប់សំបុត្រលេខ ២៤៦៧
ភ្នំពេញ

ទូរស័ព្ទ៖ +៨៥៥ ២៣ ២១៨ ០៣៤
ទូរសារ៖ +៨៥៥ ២៣ ២១១ ៩០៩
www.cambodia.panda.org

**សេចក្តីប្រកាសសារព័ត៌មាន** **សម្រាប់ការចេញផ្សាយបន្ទាន់**

| | |
|---|---|
| 12. Angkor Palace Resort & Spa | 51. Kandal House Restaurant |
| 13. Sokha Angkor Hotel | 52. Cafe Metro |
| 14. Sokha Club Hotel | 53. Le Quay Cake Cafe |
| 15. Sokha Beach Resort | 54. Anjali Restaurant |
| 16. Sofitel Phokeethra Royal | 55. Karma Restaurant |
| 17. Angkor Golf & Spa | 56. Garden Bar |
| 18. Golf Angkor Hotel | 57. River Street Restaurant |
| 19. Ree Hotel | 58. Cantina Restaurant |
| 20. Golden Sand Hotel Sihanouk ville | 59. Pink Elephant Pub |
| 21. Golden Sea Hotel & Casino | 60. Mekong River Restaurant |
| 22. Crystal Hotel Sihanouk ville | 61. Cozyna Hotel Phnom Penh |
| 23. Oasis Bungalow Resort | 62. Only You Minimart |
| 24. Koh Kong Ecotour | 63. 9 Movie World |
| 25. Koh Kong City Hotel | 64. Princess |
| 26. Sovanna Shopping Center | 65. Reak Ray Beverage Minimart |
| 27. Shopping Center Sorya | 66. Java Cafe and Gallery |
| 28. Rathana Plaza | 67. Circa 51 Hotel |
| 29. The Pizza Company | 68. Bojangles Restaurant |
| 30. The Riverhouse Lounge | 69. Indochine Hotel |
| 31. Khmer Borane Restaurant | 70. Cadillac Restaurant |
| 32. Pop Cafe | 71. Royal Inn Phnom Penh |
| 33. Vieyo Tonle Restaurant | 72. Hotel Cara |
| 34. Camory Bakery and Cafe | 73. Lebiz Hotel |
| 35. Khmersaravan Restaurant | 74. Goldiana Hotel |
| 36. Happy Herb Pizza | 75. Malis Restaurant |
| 37. Elmundo Restaurant | 76. Topaz Restaurant |
| 38. Chill Restaurant | 77. Angkor Village Hotel |
| 39. King's Court Restaurant | 78. Angkor Century resort and spa |